# សម្លេងយើង ដើម្បីសមភាពយេនឌ័រ
## សេចក្តីថ្លែងការណ៍រួម

រាជធានីភ្នំពេញ ថ្ងៃទី៧ ខែមីនា ឆ្នាំ២០១៨

សម្លេង
របស់យើងដើម្បី
សមភាពយេនឌ័រ

# អង្គការសង្គមស៊ីវិលរៀបចំកម្មវិធីផ្សព្វផ្សាយគម្រោងសមភាពយេនឌ័រ និងសូមអំពាវនាវឲ្យរដ្ឋាភិបាលបង្កើនការគាំទ្រដល់ស្ត្រី និងអ្នកស្រឡាញ់ភេទដូចគ្នា

ក្នុងឱកាសទិវានារីអន្តរជាតិនេះ អង្គការដានឈើចឺអេជ (DCA) មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា ("ម.ស.ម.ក") មជ្ឈមណ្ឌលកម្ពុជាដើម្បីប្រព័ន្ធផ្សព្វផ្សាយឯករាជ្យ និងគណៈកម្មាធិការនៃអង្គការមិនមែនរដ្ឋាភិបាលកម្ពុជាដើម្បីអនុសញ្ញាលុបបំបាត់រាល់ទំរង់នៃការរើសអើងលើស្ត្រីភេទ(NGOCEDAW) រៀបចំកម្មវិធីផ្សព្វផ្សាយគម្រោង "សម្លេងយើងដើម្បីសមភាពយេនឌ័រ" ដោយសូមអំពាវនាវដល់រាជរដ្ឋាភិបាលកម្ពុជា ("រដ្ឋាភិបាល") ធ្វើការបញ្ជាក់នូវការប្តេជ្ញាជាថ្មីចំពោះសមភាពយេនឌ័រតាមរយៈការវិសោធនកម្មច្បាប់ស្តីពីការទប់ស្កាត់អំពើហិង្សាក្នុងគ្រួសារនិងកិច្ចការពារជនរងគ្រោះ("ច្បាប់ហិង្សាក្នុងគ្រួសារ") និងចាត់វិធានការដើម្បីធានាថាស្ត្រី ក្មេងស្រី និងអ្នកស្រឡាញ់ភេទដូចគ្នាត្រូវបានការពារពីអំពើហិង្សាគ្រប់ប្រភេទ។

ស្ត្រីកម្ពុជានៅតែប្រឈមនឹងហានិភ័យខ្ពស់ពីអំពើហិង្សាផ្អែកលើយេនឌ័រ ដោយស្ត្រីដែលមានដៃគូរហូតដល់២៥% ធ្លាប់ទទួលរងការបំពារបំពានលើរូបរាងកាយ និងផ្លូវភេទ។ អ្នកស្រឡាញ់ភេទដូចគ្នា និងស្ត្រីទូទៅនៅតែប្រឈមនឹងភាពមិនស្មើគ្នា ដោយសារតែបទដ្ឋានសង្គមដែលមានលក្ខណៈរើសអើង ហើយបុគ្គលដែលហ៊ានក្រោកឈរដើម្បីទាមទារសិទ្ធិរបស់ខ្លួន ជារឿយៗប្រឈមនឹងការរើសអើងកាន់តែខ្លាំង ប្រឈមនឹងអំពើហិង្សាធ្ងន់ធ្ងរទាំងនៅក្នុងគ្រួសារ និងមជ្ឈដ្ឋានខាងក្រៅ។ ទោះបីជាក្រុមរងគ្រោះទាំងនេះបានព្យាយាមធ្វើសកម្មភាពនានាដើម្បីទាមទារសិទ្ធិទទួលបានសមភាពរបស់ពួកគេជាច្រើនឆ្នាំកន្លងមកនេះក្តី ក៏នៅតែមានកិច្ចការជាច្រើនដែលត្រូវធ្វើបន្ថែមទៀត ដើម្បីបញ្ឈប់អំពើហិង្សាផ្អែកលើយេនឌ័រ ការរើសអើងនិងដើម្បីសម្រេចឲ្យបាននូវសមភាពយេនឌ័រ។ យើងខ្ញុំជាក្រុមអង្គការដែលសហការអនុវត្តគម្រោងដូចមានរាយនាមខាងក្រោមទទួលស្គាល់នូវតួនាទីដ៏មានសារៈសំខាន់ដែលសង្គមស៊ីវិល និងសាធារណជនទូទៅក្នុងការចូលរួមលុបបំបាត់អំពើហិង្សាផ្អែកលើយេនឌ័រនៅកម្ពុជា បញ្ឈប់ការរើសអើង និងជំរុញឱ្យមានសមភាពយេនឌ័រកាន់តែប្រសើរឡើង។ ដោយហេតុនេះ យើងខ្ញុំសូមបញ្ជាក់នូវការប្តេជ្ញាចិត្តយ៉ាងមោះមុតដើម្បីចូលរួមចំណែកក្នុងបុព្វហេតុនេះ។

ប៉ុន្តែ បញ្ហាប្រឈមជុំវិញវិសមភាពយេនឌ័រ និងការរើសអើងទាំងនេះ នឹងមិនអាចដោះស្រាយបានពេញលេញនោះទេ ប្រសិនបើពុំមានការប្តេជ្ញាចិត្តខ្លាំងក្លា និងវិធានការជាក់លាក់ពីសំណាក់រដ្ឋាភិបាល ដែលមានទំនួលខុសត្រូវក្នុងការការពារសិទ្ធិមនុស្សនិងសម្រេចឲ្យបានសមភាពយេនឌ័រ ហើយយើងខ្ញុំសូមអំពាវនាវដល់អាជ្ញាធរពាក់ព័ន្ធមេត្តាបង្កើនកិច្ចប្រឹងប្រែងបន្ថែមទៀតដើម្បីសម្រេចឲ្យបាននូវគោលដៅរួមទាំងនេះ។ យើងខ្ញុំសូមកោតសរសើរចំពោះកិច្ចប្រឹងប្រែងជាបន្តរបស់រដ្ឋាភិបាលក្នុងការធ្វើវិសោធនកម្មច្បាប់ហិង្សាក្នុងគ្រួសារ និងសូមអំពាវនាវដល់ភាគីពាក់ព័ន្ធទាំងអស់ដែលចូលរួមក្នុងការដំណើរការតាក់តែងសេចក្តីព្រាងវិសោធនកម្មច្បាប់នេះ រួមទាំងក្រសួងកិច្ចការនារី ធានាឱ្យមានដំណើរការកិច្ចពិគ្រោះយោបល់វិសោធនកម្មច្បាប់នេះជាបន្តទៀត ដើម្បីឱ្យស្ត្រី ក្មេងស្រី្ត និងអ្នកស្រឡាញ់ភេទដូចគ្នានៅទូទាំងប្រទេសកម្ពុជាទទួលបានកិច្ចការពារដោយពេញ

# សម្លេងយើង ដើម្បីសមភាពយេនឌ័រ

## សេចក្ដីថ្លែងការណ៍រួម

សម្លេង របស់យើងដើម្បី សមភាពយេនឌ័រ

រាជធានីភ្នំពេញ ថ្ងៃទី៧ ខែមីនា ឆ្នាំ២០១៨

លេញពីអំពើហិង្សាគ្រប់ប្រភេទ។ យើងខ្ញុំក៏សូមស្នើដល់ក្រសួងមហាផ្ទៃបង្កើនកិច្ចខិតខំប្រឹងប្រែងក្នុងការរៀបចំវគ្គបណ្ដុះបណ្ដាលបន្ថែមទៀតដល់អាជ្ញាធរមូលដ្ឋាន រួមមាននគរបាល និងក្រុមប្រឹក្សាឃុំ/សង្កាត់ ដើម្បីបំប៉នអំពីវិធីដោះស្រាយករណីហិង្សាផ្អែកលើយេនឌ័រ ដោយផ្ដល់អទិភាពសំខាន់អំពីសុវត្ថិភាពរបស់ស្ត្រី ក្មេងស្រ្តី និងអ្នកស្រលាញ់ភេទដូចគ្នា និងការពារសិទ្ធិ និងសេចក្ដីថ្លៃថ្នូររបស់ពួកគាត់ដើម្បីកុំឱ្យមានជនរងគ្រោះណាម្នាក់មានការភ័យខ្លាចក្នុងការរាយការណ៍អំពីករណីរំលោភបំពាន ។ ម្យ៉ាងវិញទៀត យើងខ្ញុំសូមអំពាវនាវដល់រដ្ឋាភិបាលមេត្តាបំពេញកាតព្វកិច្ចរបស់ខ្លួនដើម្បីលើកកម្ពស់និងការពារសិទ្ធិរបស់ស្ត្រី និងអ្នកស្រឡាញ់ភេទដូចគ្នាទាំងអស់ក្នុងនោះរួមទាំងសិទ្ធិចូលរួមក្នុងជីវភាពសាធារណៈផងដែរ។

កម្មវិធីផ្សព្វផ្សាយគម្រោង "សម្លេងយើងដើម្បីសមភាពយេនឌ័រ" ដែលទទួលបានមូលនិធិពីសហភាពអឺរ៉ុបនិងអង្គការ DCA នៅថ្ងៃនេះនឹងចាប់អនុវត្តសកម្មភាពរហូតដល់ខែកុម្ភៈ ឆ្នាំ២០២២។ គម្រោងនេះមានគោលបំណងចូលរួមចំណែកបន្ថែមទៀតជាមួយអាជ្ញាធរថ្នាក់ជាតិ និងមូលដ្ឋានដើម្បីសម្រេចឲ្យបាននូវសមភាពយេនឌ័រឲ្យកាន់តែប្រសើរនៅក្នុងរចនាសម្ពន្ធរដ្ឋាភិបាល និងជីវភាពសាធារណៈនៅកម្ពុជាតាមរយៈមធ្យោបាយមួយដែលនឹងផ្ដល់សិទ្ធិអំណាចដល់ស្ត្រី ក្មេងស្រី និងអ្នកស្រឡាញ់ភេទដូចគ្នាដើម្បីទាមទារសិទ្ធិរបស់ខ្លួន ធានាឱ្យពួកគាត់ទទួលបានការគាំទ្របន្ថែមទៀតពីអាជ្ញាធរនិងសហគមន៍របស់ពួកគាត់ ព្រមទាំងលើកកម្ពស់ការយល់ដឹងរបស់សាធារណជន និងលុបបំបាត់ផ្នត់គំនិតអវិជ្ជមានតាមរយៈការផ្លាស់ប្ដូរឥរិយាបថ និងយុទ្ធនាការតាមប្រព័ន្ធផ្សាយព័ត៌មាន។

---


**ព័ត៌មានបន្ថែម សូមទាក់ទង ៖**

លោក ផេតធើ បូ ឡាសេន នាយកប្រចាំប្រទេស DCA តាមរយៈអ៊ីម៉ែល ៖ pbl@dca.dk

លោកស្រី ចក់ សុភាព នាយិកាប្រតិបត្តិ ម.ស.ម.ក អ៊ីម៉ែល ៖ chaksopheap@cchrcambodia.org ឬ ទូរស័ព្ទ៖ ៨៥៥ (0) ១១ ៩៤៣ ២១៣

លោក ណុប វី នាយកផ្នែកប្រព័ន្ធផ្សព្វផ្សាយ CCIM អ៊ីម៉ែល ៖ nopvy@vodhotnews.com ទូរស័ព្ទ៖ ៨៥៥ (0) ៦0 ៤0៥ ៩៩៩

លោកស្រី ជិន ចាន់នាង អគ្គលេខាធិការនៃ NGO-CEDAW អ៊ីម៉ែល ៖ ngocedaw.pnh@gmail.com ឬ ទូរស័ព្ទ៖ ៨៥៥ (0) ១២ ៦៦ ៨៨ ៥៣